ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការ
ខេត្តសៀមរាប-ឧត្តរមានជ័យ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៤៣១ ចុះថ្ងៃទី ១៦
ខែ កក្កដា ឆ្នាំ ២០០៥
សាលក្រម
លេខ ០៧ "ក" ចុះថ្ងៃទី ១៦
ខែ មករា ឆ្នាំ ២០០៦

សាលក្រមនេះចូលជាស្ថាពរ ចាប់ពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៦ ដោយបាន
ផុតកាលកំណត់ប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។
សៀមរាប, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា [redacted]

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃ រដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប នាថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជំរះ :**

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៣១ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

ឈ្មោះ **ឧ សជ** ភេទស្រី អាយុ ៤១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្កុល ឃុំតាគុយ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កំរិតវប្បធម៌មិនចេះអក្សរ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលចាប់ខ្លួន នៅភូមិបឹងដូនប៉ា ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប មុខរបរលក់ចាប់ហួយ ប្តីឈ្មោះ **ធ សម** មានកូន ០៥នាក់ ឪពុកឈ្មោះ **ឧ ឧ** (ស) ម្តាយឈ្មោះ **ឈ ន** (ស) ទោសពីមុន *គ្មាន* ។

-ចាប់ខ្លួនថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ ។

-ឃុំខ្លួនថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៥

ពីបទ **ការរក្សាទុកនូវគ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ** ប្រព្រឹត្តនៅភូមិវត្តបូព៌ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣៣ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ។



Scanned with CamScanner

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ នាង **ឧ សជ** ត្រឡប់មកពីលេងស្រុកកំណើតនៅខេត្តបាត់ដំបងវិញ ពេលមកដល់ខេត្តបន្ទាយមានជ័យ នៅគល់ស្ពានសៃសិន **ឧ សជ** បានទិញថ្នាំញៀនប្រភេទមេដំហ្វេតាមីនចំនួន ១២គ្រាប់ ពីឈ្មោះ **ឧ** "មិនស្គាល់ត្រកូល" តំលៃមួយគ្រាប់ ៣២បាតប្រាក់ថៃ ទុកសំរាប់ជក់ផ្ទាល់ខ្លួន ។ ពេលមកដល់ដេកបានមួយសន្ទុះ លុះដល់វេលាម៉ោង ១០:០០នាទីយប់ នាង **ឧ សជ** ឈឺពោះយ៉ាងខ្លាំង ដោយសារជម្ងឺគ្រុនពោះវៀនរើឡើងវិញ នាងក៏ជិះម៉ូតូឌុបដើម្បីទៅទិញទឹកកកនៅផ្សារសាមគ្គីយកមកស្អំពោះ ព្រោះនៅក្បែរផ្ទះនាង **ឧ សជ** គ្មានលក់ទឹកកក ។ ក្នុងពេលដែលនាង **ឧ សជ** មកទិញទឹកកកនោះ គឺពាក់អាវដែលនាងពាក់មកពីខេត្តបាត់ដំបង ហើយថ្នាំញៀនដែលនៅក្នុងហោប៉ៅអាវពុំបានយកទុក លុះមកដល់ចុងស្ពានថ្មនាង **ឧ សជ** ក៏ជួបសមត្ថកិច្ចឃាត់ និង ឆែកឃើញថ្នាំញៀនខាងលើ ហើយឃាត់ខ្លួន **ឧ សជ** តែម្តង ។ ថ្នាំញៀនប្រភេទមេដំហ្វេតាមីនចំនួន ១២គ្រាប់ ត្រូវនគរបាលការិយាល័យប្រឆាំងគ្រឿងញៀនបានដកធ្វើតេស្តអស់ចំនួនមួយគ្រាប់នៅសល់ចំនួន ១១គ្រាប់ត្រូវដកហូតទុកជាវត្ថុតាង ។ ក្រោយពីការធ្វើពិសោធន៍របស់អគ្គលេខាធិការដ្ឋានមន្ទីរពិសោធន៍ឃើញថាលទ្ធផលកោសល្យវិច្ច័យគ្រឿងញៀន ០១គ្រាប់មានទម្ងន់ ០,០៩២៣ក្រាម សរុបចំនួន ១១គ្រាប់មានទម្ងន់ ១,០១៥៣ក្រាម ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ **ឧ សជ** បានឆ្លើយថា ខ្លួនសូមសារភាពថា ពិតជាបានទិញថ្នាំញៀនប្រភេទមេដំហ្វេតាមីន ពីឈ្មោះ **ឧ** "មិនស្គាល់ត្រកូល" កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ ពិតប្រាកដមែន កាលនោះខ្លួនបានត្រឡប់មកពីមើលម្តាយឈឺនៅខេត្តបាត់ដំបង ពេលមកដល់ខេត្តបន្ទាយមានជ័យ នៅម្តុំស្ពានសៃសិនខ្លួនបានទិញថ្នាំញៀនពីឈ្មោះ **ឧ** "មិនស្គាល់ត្រកូល" ចំនួន ១២គ្រាប់តម្លៃមួយគ្រាប់ ៣២បាតប្រាក់ថៃ ។ ពេលទិញថ្នាំញៀនបានខ្លួនបានយកមកទុកក្នុងហោប៉ៅអាវ ។ លុះពេលត្រឡប់មកដល់ផ្ទះនៅពេលយប់ ខ្លួនបានជិះម៉ូតូឌុបពាក់អាវដែលខ្លួនពាក់មកពីខេត្តបាត់ដំបង ហើយថ្នាំញៀននៅក្នុងហោប៉ៅអាវពុំបានយកទុក លុះមកដល់ចុងស្ពានថ្មក៏ជួបសមត្ថកិច្ចឃាត់ និង ឆែកស្ទាបខ្លួន ឃើញថ្នាំញៀនដែលខ្លួនទិញមកទុកសំរាប់ជក់ចំនួន ១២គ្រាប់នោះ ហើយសមត្ថកិច្ចក៏ចាប់ខ្លួនតែម្តង ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា

ជនជាប់ចោទបានឆ្លើយសារភាពអស់ហើយ មិនខុសអ្វីពីដីកាសន្និដ្ឋានស្ថាពរ ដែលបានថ្លែងរួចមកហើយនោះទេ តាងនាមខ្ញុំជាតំណាងអយ្យការសូមតម្កល់បទចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរដដែល ។ សង្ឃឹមថាលោកចៅក្រម នឹងចេញសាលក្រមផ្តន្ទាទោសអោយបានសមស្រប និង គតិបណ្ឌិត ។

ជនជាប់ចោទបាននិយាយសំដីជាចុងក្រោយបង្អស់ថា "សូមតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនដោយក្តីអនុគ្រោះ" ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់អយ្យការ



Scanned with CamScanner

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយបង្អស់

## <u>តុលាការ</u>

ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ វេលាម៉ោង ៣:០០នាទីរសៀល ឈ្មោះ **ឆ សផ** បានរក្សាថ្នាំញៀនប្រភេទមេដំហ្វេតាមីនចំនួន ១២គ្រាប់ ក្នុងហោប៉ៅអាវរួចធ្វើដំណើរត្រូវសមត្ថកិច្ចឆែកឆេរឃើញ និង ចាប់ខ្លួន ។

-យល់ឃើញថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ **ឆ សផ** មានចែង និង ផ្តន្ទាទោសតាមមាត្រា ៣៣ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ។

-ប៉ុន្តែបើពិនិត្យអោយបានដិតដល់ទៅឃើញថា ជនជាប់ចោទជាមនុស្សអវិជ្ជាល្ងង់ខ្លៅ ខ្វះការពិចារណា ជីវភាពក្រលំបាក ហើយទើបតែប្រព្រឹត្តជាលើកដំបូង ។

-យល់ឃើញថា ថ្នាំគ្រាប់ចំនួន ១២គ្រាប់ មានពណ៌ផ្កាឈូក ចំនួន ១១គ្រាប់ និង ពណ៌បៃតង ០១គ្រាប់ គឺជាថ្នាំញៀនប្រភេទមេដំហ្វេតាមីន ដែលជនជាប់ចោទបានរក្សាប្រាកដមែន ។

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសឈ្មោះ **ឆ សផ** ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ (ពីរឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ពីបទ **ការរក្សាទុកនូវគ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ** ប្រព្រឹត្តនៅភូមិវត្តបូព៌ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣៣ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ។

២-វត្ថុតាងថ្នាំញៀនប្រភេទមេដំហ្វេតាមីន ចំនួន១១គ្រាប់ ពណ៌ផ្កាឈូកចំនួន ១១គ្រាប់ និង ពណ៌បៃតង ០១គ្រាប់ ត្រូវរឹបអូស និង បំផ្លាញចោល ។

៣-សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខតួក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ពេល ០២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

**ចៅក្រមជំនុំជំរះ**
**ហត្ថលេខា និង ត្រា**
[redacted]

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និង ត្រា**
[redacted]

**បានឃើញ**
*សៀមរាប.ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦*
**ប្រធានតុលាការខេត្ត**
[redacted]



Scanned with CamScanner